# របាយការណ៍បូកសរុបប្រចាំឆ្នាំ២០១៣ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

| | |
|---|---|
| **អង្គការ** | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") |
| **ទិសដៅគម្រោង** | ចក្ខុវិស័យរបស់ម.ស.ម.ក គឺចង់ឲ្យកម្ពុជាក្លាយទៅជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋានមានសមភាពនិងត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យនិងទទួលបាន ប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ |
| **រយៈពេល** | ពីខែមករា ដល់ខែធ្នូ ឆ្នាំ២០១៣ |

## I. សេចក្តីផ្តើម

បញ្ហាសិទ្ធិមនុស្សនៅកម្ពុជាមានការវិវឌ្ឍដែលគួរឱ្យព្រួយបារម្ភមួយចំនួនក្នុងពេលធ្វើរបាយការណ៍នេះ។ នៅឆ្នាំ២០១៣ សកម្មជនដីធ្លី អ្នកសារព័ត៌មានវិជ្ជាជីវៈ ថ្នាក់ដឹកនាំសហជីព និងអ្នកធ្វើការងារផ្នែកសិទ្ធិមនុស្សនៅក្នុងប្រទេសប្រឈមនឹងការគំរាមកំហែងផ្លូវច្បាប់ ការចាប់ខ្លួនតាមអំពើចិត្តនិងការគំរាមសម្លាប់។ ក្នុងចំណោមស្ថានភាពអាក្រក់បែបនេះ ក៏មានស្ថានភាពវិវឌ្ឍគួរឱ្យកត់សម្គាល់មួយចំនួនក្នុងឆ្នាំ២០១៣ ផងដែរ។ រយៈពេលប៉ុន្មានខែនៅមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលនឹងបានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ប្រជាពលរដ្ឋរាប់ពាន់នាក់ រួមមានទាំងយុវជនក្មេងៗផងដែរបានចូលរួមដង្ហែក្បួនតាមដងវិថីជាការគាំទ្រដល់គណបក្សជំទាស់ដ៏ធំគឺគណបក្សសង្គ្រោះជាតិ("គ.ស.ជ")។ ការពុំមានការរឹតបន្តឹងខ្លួនឯងក្នុងចំណោមយុវជនដែលពុំធ្លាប់ឆ្លងកាត់ដោយផ្ទាល់ក្នុងសោកនាដកម្មនាពេលកន្លងមករបស់ប្រទេសកម្ពុជាគឺជាសញ្ញាវិជ្ជមានបំផុតសម្រាប់អនាគតនៃសិទ្ធិមនុស្សនិងការអភិវឌ្ឍនៅក្នុងប្រទេស។ មានចលាចលតិចតួចនិងពុំមានការឃាយីទៅលើរាងកាយពីសំណាក់អាជ្ញាធរ ដូចដែលបានឃើញក្នុងអំឡុងពេលនៃការបោះឆ្នោតមុនៗឡើយ។ ប៉ុន្តែ ក្នុងរយៈពេលពីរបីខែចុងក្រោយក្នុងឆ្នាំ២០១៣ បាតុកម្មដោយសន្តិវិធីជាញឹកញាប់បានប្រែក្លាយជាហិង្សាដោយមានការប្រើកម្លាំងពុំសមមាត្រពីសំណាក់កម្លាំងសន្តិសុខរបស់រដ្ឋ។ បាតុកម្មត្រូវបានបង្ក្រាបយ៉ាងហិង្សាពីសំណាក់អាជ្ញាធរប្រើប្រាស់អាវុធស្វ័យប្រវត្តិ កាំភ្លើង ឧស្ម័នបង្ហូរទឹកភ្នែក ឡានបាញ់ទឹក និងដំបងដើម្បីវាយបំបែកអ្នកតវ៉ា។ មានការបាញ់ប្រហារពីកម្លាំងសន្តិសុខនៅកន្លែងបាតុកម្មដែលបណ្តាលឱ្យមនុស្សស្លាប់ពីរនាក់ និងម្នាក់ទៀតពិការជាអចិន្ត្រៃយ៍ ហើយយ៉ាងតិចមនុស្សចំនួន១៦នាក់ផ្សេងទៀតបានរងរបួស។ មានបាតុករជាច្រើននាក់រងការវាយដំ ដោយមានស្ត្រី

បីនាក់បានរលូតកូន។[1] បាតុកម្មនានាទាំងនេះធ្វើឡើងដោយកម្មកររោងចក្រកាត់ដេរដែលបានធ្វើការតវ៉ាជាញឹកញាប់ និងបានធ្វើកូដកម្មជំទាស់ទៅនឹងប្រាក់ឈ្នួលទាប និងលក្ខខណ្ឌការងារមិនល្អប្រសើរ ហើយសកម្មជនផ្នែកសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋានប្រឈមនឹងការបណ្តេញចេញ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ ការតវ៉ាមួយរបស់កម្មកររោងចក្រកាត់ដេរអេស អិល នៅខណ្ឌមានជ័យ ក្នុងរាជធានីភ្នំពេញបាននាំឱ្យស្ត្រីម្នាក់ត្រូវបានកម្លាំងសន្តិសុខបាញ់សម្លាប់និងប្រាំបួននាក់ផ្សេងទៀតបានរងរបួស។ បន្ថែមទៅលើការប្រើប្រាស់កម្លាំងហួសហេតុពីសំណាក់អាជ្ញាធរ អ្នកតវ៉ាជាង៤០នាក់ត្រូវបានចាប់ខ្លួន ក្នុងនោះរួមមានទាំងព្រះសង្ឃផងដែរ។[2]

## II. ទិន្នភាព

ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ម.ស.ម.ក បានចេញផ្សាយសេចក្តីថ្លែងការណ៍/វិចារណកថាព័ត៌មាន/លិខិតចំហចំនួន៥១ សេចក្តីប្រកាសព័ត៌មានផ្នែកអ្នកការពារសិទ្ធិមនុស្សនិង/ឬសេរីភាពខាងការបញ្ចេញមតិចំនួន៥ កំណត់ត្រាសង្ខេបចំនួន៣ របាយការណ៍ស្រាវជ្រាវចំនួន៤ សលាកប័ត្រព័ត៌មានចំនួន៣ ការវិភាគច្បាប់១ និងឯកសារចំនួន៦ ផ្សេងទៀត (រួមមានសារណាទៅកាន់ក្រុមការងារត្រួតពិនិត្យជាសកលតាមកាលកំណត់របស់អង្គការសហប្រជាជាតិ សៀវភៅណែនាំអំពីនីតិវិធីមួយនិងលទ្ធផលរបាយការណ៍នៃកម្មវិធីសិក្ខាសាលា/គោលនយោបាយសង្ខេបចំនួនបី)។ ឯកសារទាំងនេះបានគ្របដណ្តប់ទៅលើបញ្ហាសិទ្ធិមនុស្សផ្សេងៗជាច្រើនចាប់តាំងពីសិទ្ធិដីធ្លី ធុរកិច្ច និងសិទ្ធិមនុស្ស តំណាងនយោបាយរបស់ស្ត្រី កំណែទម្រង់នយោបាយ/ការបោះឆ្នោត/អភិបាលកិច្ច សេរីភាពខាងការបញ្ចេញមតិ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ កំណែទម្រង់ផ្នែកតុលាការ (រួមទាំង សាលាជម្រះក្តីខ្មែរក្រហម) អ្នកការពារសិទ្ធិមនុស្ស សិទ្ធិជនជាតិដើម និងបញ្ហាផ្សេងៗទៀត។ លើសពីនេះ ម.ស.ម.ក បានរៀបចំកម្មវិធីពិភាក្សាវិទ្យុចំនួន៧៨ លើកដែលពិភាក្សាពាក់ព័ន្ធនឹងសិទ្ធិដីធ្លីនិងអ្នកការពារសិទ្ធិមនុស្ស)។ ម.ស.ម.ក បានរៀបចំកម្មវិធីពិភាក្សាវិទ្យុមួយនិងសិក្ខាសាលាមួយទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ និងវេទិកាគោលនយោបាយមួយទាក់ទងនឹងសិទ្ធិដីធ្លី ព្រមទាំងបានរៀបចំការបណ្តុះបណ្តាលចំនួន១៤លើកទាក់ទងនឹងប្រធានបទផ្សេងៗ ចាប់តាំងពីបច្ចេកវិទ្យាព័ត៌មាន បណ្តាញផ្សព្វផ្សាយព័ត៌មានសង្គម សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រហូតដល់វិធានសន្តិសុខសម្រាប់អ្នកការពារសិទ្ធិមនុស្ស។

ជាងនេះទៅទៀត ក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ ម.ស.ម.ក បានរៀបចំយុទ្ធនាការមួយនៅមុនទិវាបញ្ឈប់និទណ្ឌភាពអន្តរជាតិនៅថ្ងៃទី២៣ ខែវិច្ឆិកា។ ជាផ្នែកនៃយុទ្ធនាការនោះ ម.ស.ម.ក បានលើកឡើងនូវករណីនិទណ្ឌភាពសម្រាប់ពលរដ្ឋកម្ពុជាមួយចំនួនក្នុងនោះរួមមានទាំងអ្នកការពារសិទ្ធិមនុស្ស សកម្មជន និងអ្នកសារព័ត៌មាន

---

[1] កំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក "ការប្រើប្រាស់កម្លាំងហួសហេតុទៅលើបាតុករក្នុងឆ្នាំ២០១៣ នៅកម្ពុជា" ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៣http://bit.ly/2fdWzUL

[2] ចូហៅ លីប៉េស ស្ត្រីម្នាក់ត្រូវបាននគរបាលកម្ពុជាបាញ់សម្លាប់ក្នុងការបង្ក្រាបលើការតវ៉ា" វិទ្យុអាស៊ីសេរី (ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣) http://bit.ly/1erpIDd.

ដែលរងការយាយី ឬសម្លាប់ ដូចជា លោក ជា វិជ្ជា មេដឹកនាំសហជីព លោក ឈុត វុទ្ធី សកម្មជនផ្នែកបរិស្ថាន និង លោកហង្ស សិរីឧត្តម អ្នកសារព័ត៌មានជាដើម។

### III. សកម្មភាពដែលដំណើរការបានល្អ និងមិនល្អ

នៅចុងខែសីហា ឆ្នាំ២០១៣ ម.ស.ម.ក បានចេញផ្សាយសៀវភៅមគ្គុទ្ទេសក៍ស្តីពីនីតិវិធីព្រហ្មទណ្ឌនៅតុលាការកម្ពុជាៈនីតិវិធីមុនការជំនុំជម្រះនិងការជំនុំជម្រះ ក្រោមគម្រោងសង្កេតការណ៍សវនាការរបស់ខ្លួនក្នុងគោលបំណងជួយអ្នកការពារសិទ្ធិមនុស្សនិងក្រុមគ្រួសាររបស់ខ្លួន មេធាវីការពារក្តីនិងសង្គមស៊ីវិលឲ្យទទួលបានការយល់ដឹងប្រសើរអំពីនីតិវិធីព្រហ្មទណ្ឌកម្ពុជាតាមរយៈការបង្កើតគោលការណ៍ណែនាំដែលងាយស្រួល។ សាធារណជន និងរដ្ឋាភិបាលទទួលបានសៀវភៅនេះ ព្រមទាំងមនុស្សជាច្រើនបានស្នើសុំជាសៀវភៅបោះពុម្ពនេះ រួមមានតំណាងពីក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងគណៈមេធាវីផងដែរ។ ក្រៅពីនេះមានឯកសារបោះពុម្ពផ្សាយជាច្រើនផ្សេងទៀតក្រោមគម្រោងសង្កេតការណ៍សវនាការ ក្នុងនោះរួមមាន កំណត់ត្រាសង្ខេបស្តីពីការអនុវត្តវិធានការឃុំខ្លួនបណ្តោះអាសន្ននៅតុលាការកម្ពុជា (ខែកក្កដា ឆ្នាំ២០១៣) និងកំណត់ត្រាសង្ខេបស្តីពី ការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ខែតុលា ឆ្នាំ២០១៣) ដែលត្រូវបានបណ្តាញព័ត៌មានជាតិនិងអន្តរជាតិផ្សព្វផ្សាយជាច្រើន។ ឧទាហរណ៍ អ្នកសម្របសម្រួលគម្រោងសង្កេតការណ៍សវនាការនៃម.ស.ម.ក ត្រូវបានកាសែតthe Wall Street Journalសម្ភាសន៍តាមរយៈស្កៃប(Skype)ដោយបានពិភាក្សាអំពីសេចក្តីថ្លែងការណ៍លើការបិទបញ្ចប់សំណុំរឿងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងកំណត់ត្រាសង្ខេបដែលត្រូវបានដកស្រង់នៅក្នុងអត្ថបទព័ត៌មានមួយរបស់សារព័ត៌មានសំឡេងសហរដ្ឋអាមេរិក។

តាមរយៈគម្រោងសិទ្ធិ(Sithi) ដែលជាគេហទំព័រសិទ្ធិមនុស្សទទួលបានពានរង្វាន់របស់ម.ស.ម.ក www.sithi.org បានទទួលមូលនិធិបង្កើតសិទ្ធិហាប់"Sithi Hub" ។ សិទ្ធិហាប់គឺជាកន្លែងមួយស្ថិតនៅក្នុងរាជធានីភ្នំពេញដែលផ្តល់នូវធនធាននិងឧបករណ៍នានាសម្រាប់សកម្មជនវ័យក្មេងនិងអ្នកមានជំនាញផ្នែកឆ្នៃប្រឌិត ដូចជាអ្នកសរសេរប្លុក បច្ចេកវិទ្យាព័ត៌មាន អ្នកជំនាញ និងអ្នកអភិវឌ្ឍគេហទំព័រ ហើយក៏ដូចជាអ្នកធ្វើការងារផ្នែកសិទ្ធិមនុស្សដើម្បីទាញប្រយោជន៍ពីបណ្តាញអ៊ីនធឺណិតនិងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍និងដើម្បីអភិវឌ្ឍ និង/ឬផ្សាំទៅនឹងបច្ចេកវិទ្យាថ្មីដើម្បីការពារសិទ្ធិមនុស្ស និងសេរីភាពខាងការបញ្ចេញមតិជាពិសេស។ សិទ្ធិហាប់ ជាទីកន្លែងសម្រាប់សមាជិកធ្វើការងារ និងជាកន្លែងសម្រាប់ធ្វើការបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពរបស់សមាជិកក្នុងការប្រើប្រាស់ឧបករណ៍ថ្មីៗ និងរបៀបសម្រាប់ផ្លាស់ប្តូរសិទ្ធិមនុស្ស។

### IV. មេរៀន

ការបន្តជាប់គាំងនយោបាយដែលកើតឡើងពីការបោះឆ្នោតថ្នាក់ជាតិនៅខែកក្កដា ឆ្នាំ២០១៣ បានជះឥទ្ធិពលយ៉ាងសំខាន់ទៅលើការងាររបស់ម.ស.ម.ក។ ខណៈដែលបច្ចុប្បន្ននេះរដ្ឋាភិបាលត្រូវបានគ្រប់គ្រងដោយគណបក្សតែមួយ ដោយសារថាគណបក្សជំទាស់បន្តធ្វើពហិកាចូលរដ្ឋសភា (គិតមកដល់ពេលតាក់តែង

របាយការណ៍នេះ) មានការរឹតត្បិតឱកាសនៅពាក់កណ្តាលឆមាសនៃឆ្នាំ២០១៣ សម្រាប់ម.ស.ម.ក ធ្វើការតស៊ូមតិដើម្បីផ្លាស់ប្តូរស្ថានភាពសិទ្ធិមនុស្សដូចដែលខ្លួនធ្វើសព្វដងនាពេលកន្លងមក។ ដំណាលគ្នានេះ ការដាប់គាំងផ្នែកនយោបាយបានតម្រូវឱ្យ ម.ស.ម.ក ឆ្លើយតបទៅនឹងស្ថានភាពនានាដែលជាធម្មតាអង្គការពុំធ្វើការងារផ្តោតទៅលើកំណែទម្រង់ផ្នែកនយោបាយ អភិបាលកិច្ច និងបោះឆ្នោតនោះឡើយ។ ដោយសារ "ករណីសិក្សា" ដ៏ធំបំផុតនៅរយៈពេលពីរបីខែកន្លងមកនេះនាំឱ្យម.ស.ម.ក ត្រូវតែរក្សាសមត្ថភាពខាងក្នុងឱ្យបានគ្រប់គ្រាន់ដើម្បីបត់បែនទៅតាមការវិវឌ្ឍនានានៅកម្ពុជា ព្រមទាំងរក្សាទុកគម្រោងសំខាន់ៗមួយចំនួនមានធនធាននានា (ជាពិសេសធនធានមនុស្ស) ដើម្បីឆ្លើយតបទៅនឹងការវិវឌ្ឍនេះដោយពុំចាំបាច់បន្តចំណាយធនធានលើការងារគម្រោងជាក់លាក់ទាំងនោះ។

## V. យេនឌ័រ និងគោលការណ៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន

ម.ស.ម.ក ប្រឹងប្រែងដើម្បីសម្រេចនូវសមភាពយេនឌ័រនៅក្នុងកម្មវិធីនិងគម្រោងទាំងអស់។ តាមរយៈការបន្តគម្រោងលើកកម្ពស់ស្ត្រីក្នុងវិស័យនយោបាយ ម.ស.ម.ក ផ្តោតជាពិសេសទៅលើការតស៊ូមតិសម្រាប់លើកកម្ពស់ភាពជាតំណាងនយោបាយរបស់ស្ត្រីនៅថ្នាក់ជាតិនិងមូលដ្ឋាន ខណៈដែលកំពុងបន្តឆ្លើយតបទៅនឹងបញ្ហានានាទាក់ទងនឹងសិទ្ធិរបស់ស្ត្រីក្នុងស្ថានភាពទូទៅជានិច្ចកាល។ជាការកត់សម្គាល់នៅដើមខែធ្នូ ឆ្នាំ២០១៣ ម.ស.ម.ក បានចេញឯកសារបន្ថែមទៅលើរបាយការណ៍ខែមីនា ឆ្នាំ២០១៣ របស់ខ្លួនស្តីពី " នយោបាយក្នុងព្រះរាជាណាចក្រ៖បង្កើនតំណាងស្ត្រី" ដែលបានលើកឡើងពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅខែកក្កដា ឆ្នាំ២០១៣ និងមានការពាក់ព័ន្ធនឹងកម្រិតនៃភាពជាតំណាងស្ត្រីក្នុងវិស័យនយោបាយ។

ក្នុងនាមជាអង្គការសិទ្ធិមនុស្ស ម.ស.ម.ក បានអនុវត្តវិធីសាស្ត្រតស៊ូមតិដើម្បីឱ្យទទួលបានសិទ្ធិស្មើគ្នាប្រកបដោយគោលការណ៍សម្រាប់ការងារទាំងអស់របស់ខ្លួន។ ឧទាហរណ៍សំខាន់មួយនៃគោលជំហររបស់ ម.ស.ម.ក ទាក់ទងនឹងជំទាស់ទៅនឹងការលើកឡើងដោយរើសអើងទៅលើជនជាតិវៀតណាមរបស់គណបក្សជំទាស់នៅកម្ពុជា ជាដើម។ ដំណាលគ្នានេះ ម.ស.ម.ក ទទួលនូវប្រតិកម្មតប និងពេលខ្លះប្រតិកម្មហិង្សាទៅលើបញ្ហានេះ (សូមមើលសេចក្តីថ្លែងការណ៍ម.ស.ម.ក និងសេចក្តីអំពាវនាវបន្ទាន់របស់អង្គការប្រឆាំងទារុណកម្មអន្តរជាតិ (OMCT)។ ម.ស.ម.ក នៅតែមានជំនឿយ៉ាងមុតមាំថាក្នុងនាមជាអង្គការសិទ្ធិមនុស្ស អង្គការត្រូវតែរក្សាគោលជំហរមិនប្រកាន់និន្នាការនយោបាយ តស៊ូមតិដើម្បីទទួលបានសិទ្ធិស្មើគ្នា និងហ្មត់ចត់នៅរាល់ការងាររបស់ខ្លួន៕

**--- ចប់ ---**